


# របាយការណ៍សង្ខេប
# ស្តីពី
# សមិទ្ធផលសំខាន់ៗមួយចំនួន
# របស់
# រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០១២-២០១៦

## ផ្នែក៖ សមភាពយេនឌ័រ

ឯកសារ៖ bit.ly/Govt5th

## ផ្នែក៖ សមភាពយេនឌ័រ

**ក្រសួងកិច្ចការនារី បាន៖**

- ចងក្រងជាក្រុមផលិតនិងក្រុមសន្សំប្រាក់ចំនួន២១១ក្រុម លើជំនាញសិប្បកម្ម កសិកម្ម កែច្នៃអាហារ ជំនាញគ្រប់គ្រងអាជីវកម្ម និងការអប់រំបំណិនជីវិតក្នុងខេត្តចំនួន៥។
- គាំទ្រក្នុងការបង្កើត និងដំណើរការសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) និងសហព័ន្ធស្ត្រី (CWBF) អ្នកជំនួញកម្ពុជា បានសមាជិកសរុបចំនួន ៥០០នាក់។
- បង្កើតថ្នាក់អក្ខរកម្មសម្រាប់កម្មករ កម្មការិនីរោងចក្រចំនួន ១៩២៦នាក់ (ស្រី ១៥៥៩នាក់)
- អប់រំផ្សព្វផ្សាយ ឲ្យមានការផ្លាស់ប្តូរឥរិយាបថសង្គម ពិសេសទាក់ទងនឹងទិវានៃក្តីស្រឡាញ់ ១៤កុម្ភៈ។
- ចូលរួមជំរុញ និងគាំទ្រដល់ដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅភូមិចំនួន ១៣៧ ក្នុងខេត្ត ក្រុងចំនួន ១២។

## ផ្នែកៈ សមភាពយេនឌ័រ (ត)

### ❋ ការងារយេនឌ័រ

- បានបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ដីធ្លី។
- បានបង្កើត និងអភិវឌ្ឍន៍សមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រ តាមក្រសួងស្ថាប័នទាំង២៨
- ក្រសួងចំនួន២៤ មានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងទទួលបានថវិកាជាតិ និងថវិកាដៃគូសម្រាប់អនុវត្តការងារយេនឌ័រតាមវិស័យ។



## ផ្នែកៈ សមភាពយេនឌ័រ (ត)

### ❋ ស្ត្រី និងសុខភាព

- បានរៀបចំកែសម្រួលគោលនយោបាយស្តីពីស្ត្រី ក្មេងស្រី មេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងបង្កើនការយល់ដឹងដល់ប្រជាជន។
- បង្កើនចំណេះដឹងមូលដ្ឋាន អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការកសាងទំនាក់ទំនងរវាងមាតា និងយុវតីស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ មូលដ្ឋានគ្រឹះអំពីបទដ្ឋានអប្បបរមា សម្រាប់ផ្តល់ប្រឹក្សាដល់ជនរងគ្រោះជាស្ត្រី និងកុមារ។
- បានកសាងសមត្ថភាពដល់មន្ត្រីមន្ទីរកិច្ចការនារីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងភ្នាក់ងារអប់រំសុខភាពភូមិ ស្តីពីជំងឺគ្រុនចាញ់ និងសុខភាពភ្នែក។

## ផ្នែក៖ សមភាពយេនឌ័រ (ត)

**⁕ ស្ត្រី និងការអប់រំ**

- បានរៀបចំវេទិកាពិគ្រោះយោបល់ដើម្បីផ្លាស់ប្តូរឥរិយាបទ និងរួមចំណែកលើកកម្ពស់សីលធម៌សង្គម និងបានអភិវឌ្ឍសមត្ថភាពគ្រូបង្គោលមន្ទីរកិច្ចការនារី ដើម្បីផ្សព្វផ្សាយបន្តអំពីសិទ្ធិស្ត្រីក្នុងការគ្រប់គ្រងលើអចលនទ្រព្យ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសិល្បៈក្នុងការរស់នៅ។

**⁕ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ**

- គម្រោងចំនួន៥ ត្រូវបានអនុវត្តក្នុងខេត្តគោលដៅចំនួន៩ ដោយបានអភិវឌ្ឍសមត្ថភាពជនបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបានសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក ពន្លឺព្រះអាទិត្យ ឬប្រព័ន្ធសូឡា អណ្តូងទឹកស្អប់ ធ្វើបង្គន់អនាម័យសម្រាប់សិស្សស្រី និងបានតបណ្តាញចែកចាយទឹកបន្ថែមដល់កសិករនៅក្នុងខេត្តគោលដៅ។



## ផ្នែក៖ សមភាពយេនឌ័រ (ត)

**⁕ ការអភិវឌ្ឍស្ថាប័ន**

បានអភិវឌ្ឍសមត្ថភាពដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី លើជំនាញចំណេះដឹងតាមវិស័យនៃផែនការយុទ្ធសាស្ត្រ នារីរតនៈ ដោយប្រើប្រាស់ថវិកាជាតិតាមកម្មវិធី ស្តីពី៖

- ការវិភាគយេនឌ័រនិងជំនាញសម្របសម្រួលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងយេនឌ័រ និងការធ្វើអាជីវកម្ម កាត់ដេរ តម្បាញ សំអាងការ និងអ៊ុតសក់។
- ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ទប់ស្កាត់ការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងចំណាកស្រុក ការសរសេរបណ្តឹង និងកំណត់ហេតុស្របតាមនីតិវិធីតុលាការ។

## ផ្នែកៈ សមភាពយេនឌ័រ (ត)

### ❋ ការអភិវឌ្ឍស្ថាប័ន (ត)

- លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ និងសុខុមាលភាពសង្គម និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីពិការ។
- សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងសរសេររបាយការណ៍ណែនាំពីនីតិវិធីសវនកម្ម និងនីតិវិធីចំណាយតាមកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រៀបចំផែនការ ស្ថិតិ ត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបយេនឌ័រ។
- កិច្ចការស្ត្រី និងអាស៊ាននិងការចុះអនុស្សារណៈយោគយល់គ្នារវាងក្រសួង និងដៃគូអភិវឌ្ឍន៍។



### ❋ សមាមាត្រស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច

| បរិយាយ | ២០១២ | ២០១៦ |
|---|---|---|
| ស្ត្រីជាសមាជិកព្រឹទ្ធសភា | ៩នាក់ (១៤.៧៥%) | ១០នាក់ (១៦.៣៩%) |
| ស្ត្រីជាសមាជិករដ្ឋសភា | ២៦នាក់ (២១.១៣%) | ២៥នាក់ (២០.៣២%) |
| ស្ត្រីជារដ្ឋមន្ត្រី | ២នាក់ | ៣នាក់ |
| ស្ត្រីជារដ្ឋលេខាធិការ | ១៦នាក់ | ៣៧នាក់ |
| ត្រីជាអនុរដ្ឋលេខាធិការ | ៣៣នាក់ | ៥៤នាក់ |
| ស្ត្រីជាអភិបាលរងខេត្ត រាជធានី | ២៤នាក់ | ២៧នាក់ |
| ស្ត្រីជាអភិបាលស្រុក ក្រុង | ២នាក់ | ៦នាក់ |
| ស្ត្រីជាអភិបាលរងស្រុក ក្រុង | ១៩៤នាក់ | ១៩១នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាខេត្ត | ៣៧នាក់ | ៥៥នាក់ |
| ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | | ៦នាក់ |

## ⁕ សមាមាត្រស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច (ត)

| បរិយាយ | ២០១២ | ២០១៦ |
|---|---|---|
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៤០៦នាក់ | ៣៩៤នាក់ |
| ស្ត្រីជាមេឃុំ ចៅសង្កាត់ | ៩៦នាក់ | ១១២នាក់ |
| ស្ត្រីជាជំទប់ទី១ | ១៨៩នាក់ | ២១៤នាក់ |
| ស្ត្រីជាជំទប់ទី២ | ១៥១នាក់ | ១៥៥នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ | ២ ០៣៨នាក់ | ១ ៨៣៧នាក់ |
| ស្ត្រីជាចៅក្រម | ៣៤នាក់ | ៤០នាក់ |
| ស្ត្រីជាព្រះរាជអាជ្ញា | ១៥នាក់ | ២៣នាក់ |
| ស្ត្រីជាក្រឡាបញ្ជី | ១២៥នាក់ | ១៥៩នាក់ |
| ស្ត្រីជាមន្ត្រីរាជការ | ៣៥% | ៤០% |
| ស្ត្រីជាមន្ត្រីរាជការ ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមស្រុក ដល់ ថ្នាក់អគ្គនាយក | ១៩% | ២២% |



# ផ្នែកៈ សមភាពយេនឌ័រ (ត)

## ⁕ សមាមាត្រស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច (ត)

ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិនិងក្រោមជាតិមានសមត្ថភាពក្នុងការបំពេញការងារ និងដោះស្រាយបញ្ហាដែលពាក់ព័ន្ធស្ត្រី និងកុមារ។

## ⁕ ស្ត្រី និងកិច្ចការពារផ្លូវច្បាប់

- បានអនុម័ត និងអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១២-២០១៨ និងក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋានមានផែនការប្រតិបត្តិការប្រចាំឆ្នាំ។
- បានធ្វើការវិភាគស៊ីជម្រៅលើទិន្នន័យ ស្តីពីបទពិសោធន៍របស់ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សានៃការអង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS) ២០១៤ ភាគរយអំពើហិង្សាពីដៃគូស្និទ្ធស្នាលដែលកើតឡើងអំឡុងពេល១២ខែកន្លងមក ធៀបនឹងអំពើហិង្សាក្នុងមួយជីវិតមានការថយចុះ។

## ផ្នែកៈ សមភាពយេនឌ័រ (ត)

✻ **ស្ត្រី និងកិច្ចការពារផ្លូវច្បាប់** (ត)

- ក្រសួងកិច្ចការនារី បានសម្របសម្រួលជាមួយក្រសួងស្ថាប័នចំនួន ១៣ ក្នុងការបន្តរៀបចំផែនការសកម្មភាពជាតិ ឆ្លើយតបចំពោះហិង្សាលើកុមារ។
- បានពង្រឹង និងពង្រីកការផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (One Stop Services Center) ដែលស្ថិតក្រោមគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារថ្នាក់ខេត្តនិងស្រុកនៅក្នុងខេត្តចំនួន៧និងបណ្តុះបណ្តាលអ្នកផ្តល់សេវាចំនួន២៥០នាក់។
- មន្ត្រីក្រសួងកិច្ចការនារីចំនួន៩៤រូប (ស្ត្រី៨៥រូប) ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។
- បានដឹកនាំក្រុមការងារអន្តរក្រសួងដើម្បីរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី ការគ្រប់គ្រងការពពោះជំនួស។



## ផ្នែកៈ សមភាពយេនឌ័រ (ត)

✻ **ស្ត្រី និងកិច្ចការពារផ្លូវច្បាប់** (ត-ចប់)

- ក្រុមការងារកម្ពុជាប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (COMMIT) ដឹកនាំសម្របសម្រួលដោយក្រសួងកិច្ចការនារី បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាក្នុងការប្រឆាំងអំពើជួញដូរមនុស្ស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) និងបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន០១លើក ថ្នាក់មន្ត្រីជាន់ខ្ពស់ខមមីតលើកទី១០ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៤ ដើម្បីពិនិត្យការងារដែលបានអនុវត្តកន្លងមក និងអនុម័តនូវផែនការសកម្មភាព (ឆ្នាំ២០១៥-២០១៨) ព្រមទាំងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមទី៣ស្តីពីការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។
- បានរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម ចំនួន០២លើក ដើម្បីកែសម្រួលកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០១២។

លោកស្រី លោក អ្នកនាង កញ្ញា អាចទាញយក

**របាយការណ៍សង្ខេប ស្តីពី សមិទ្ធផលសំខាន់ៗមួយចំនួន**

**របស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦**

តាមរយៈតំណភ្ជាប់៖ bit.ly/Govt5th

សូមអរគុណ!